ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គ្រួសារបីឃុំ
## រយៈពេល ៣ ឆ្នាំ ( មីនា ២០១៨ - កុម្ភៈ ២០២១ )

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ គ្រួសារបីឃុំ |
| ភូមិ | ៖ ព្រៃកកក់ ព្រៃកបាក់ ព្រៃករលួស និងព្រះអង្គ |
| ឃុំ | ៖ ព្រៃកបាក់ |
| ភូមិ | ៖ មន្ទីរ មាឃ១ ព្រៃកបារាំង ព្រះត្នោតតាសយ ទួលពោធិ៍ និងអណ្តូងពេជ្រ |
| បុំ | ៖ ព្រៃកកក់ |
| ភូមិ | ៖ ថ្មី ដូនទរ តាមើង ធំ វត្ត សំពៀងលើ និងសំពៀងក្រោម |
| ឃុំ | ៖ ទួលព្រះឃ្លាំង |
| ស្រុក | ៖ ស្ទឹងត្រង់ |
| ខេត្ត | ៖ កំពង់ចាម |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គ្រួសារបីឃុំ
# រយៈពេល ៣ ឆ្នាំ ( មីនា ២០១៨ - កុម្ភៈ ២០២១ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | គ្រួសារបីឃុំ |
| ភូមិ | ៖ | ព្រៃកកក់ ព្រៃកបាក់ ព្រៃករលួស និងព្រះអង្គ |
| ឃុំ | ៖ | ព្រៃកបាក់ |
| ភូមិ | ៖ | មន្ទីរ មាយ១ ព្រៃកបារាំង ព្រះត្នោតតាសយ ទួលពោធិ៍ និងអណ្តូងពេជ្រ |
| ឃុំ | ៖ | ព្រៃកកក់ |
| ភូមិ | ៖ | ថ្មី ដូនទរ តាមើង ធំ វត្ត សំពៀងលើ និងសំពៀងក្រោម |
| ឃុំ | ៖ | ទួលព្រះឃ្លាំង |
| ស្រុក | ៖ | ស្ទឹងត្រង់ |
| ខេត្ត | ៖ | កំពង់ចាម |

## មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**.........១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**.........១

ក- ប្រជាពលរដ្ឋ.........១

ខ- មុខរបរ.........២

**៣- កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**.........២

ក- ទីតាំង.........២

ខ- ដែននេសាទ.........៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស.........៣

ឃ- ធនធានជលផល.........៣

**៤- ការធ្វើនេសាទ**.........៤

ក- អ្នកនេសាទ.........៤

ខ- ឧបករណ៍នេសាទ.........៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ.........៦

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**.........៦

ក- ទស្សនៈវិស័យ.........៦

ខ- គោលបំណង.........៦

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.........៦

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ.........៦

គ២- ផែនការកែលម្អកន្លែងនេសាទសហគមន៍.........៧

គ៣- ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស.........៨

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក.........៨

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល.........៩

គ៦- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ.....១០

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល.........១១

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.........១២

គ៩- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ.........១៣

គ១០- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.........១៤

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ.........១៤

គ១២- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍.........១៥

ឃ. ផែនការយុទ្ធសាស្ត្រ.........១៦

តារាងកម្មវិធីការងារ.........១៧

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទគ្រួសារបីឃុំ បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១០ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ។

សហគមន៍នេសាទគ្រួសារបីឃុំ មានទីតាំងស្ថិតនៅភូមិព្រៃកកក់ ព្រៃកបាក់ ព្រៃករលួស និងភូមិព្រះអង្គ ឃុំព្រៃកបាក់, ភូមិថ្មី ដូនទរ តាមើង ភូមិធំ ភូមិវត្ត សំពៀងលើ និងភូមិសំពៀងក្រោម ឃុំទួលព្រះឃ្លាំង និងភូមិមន្ទីរ មាយ១ ព្រៃកបារាំង ត្នោតតាសយ ទួលពោធិ៍ អណ្តូងពេជ្រ និងភូមិព្រះ ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលមានសមាជិកសរុបចំនួន១.៣៤៥នាក់ ស្រីចំនួន៤២២នាក់ ហើយមានគណៈកម្មការចំនួន១១នាក់ ស្រីគ្មាន ។ និងមានក្រុមល្បាតចំនួន១១នាក់ ។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិកនិងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍
- ការពារព្រៃលិចទឹក
- បង្កើតកន្លែងអភិរក្សត្រីមេពូជ
- ការពារកន្លែងអភិរក្សត្រីមេពូជ
- ចូលរួមសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃដំណើរការអនុវត្តន៍ការគ្រប់គ្រងសហគមន៍នេសាទ
- ទស្សនកិច្ចសិក្សា
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក
- បង្កើតក្រុមមុខរបរ (ចិញ្ចឹមសត្វ ដាំបន្លែ ក្រុមឥណទាន)
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន២៥.២៩០ ប្រុស១២.៣៩២ ស្រី១២.៨៩៨នាក់ ត្រូវជា ៥.៣១២ គ្រួសារ ក្នុងនោះមានជនជាតិខ្មែរចំនួន២៥.០៣៧នាក់ ជនជាតិតស្លាមចំនួន២៥៣នាក់។

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១៣នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៤នាក់ ស្រី១នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៤នាក់ ស្រី៨នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទចំនួន៧ នាក់ ស្រី៣ នាក់

-ចំនួនអ្នកជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៨នាក់ ស្រី០៤នាក់

-ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ៩៩%។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរចំនួន១៤៨ នាក់ ស្រី ៧៩នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៦៧៥នាក់ ស្រី១៧៦នាក់ កម្រិតមធ្យមសិក្សាចំនួន៤៨៧នាក់ ស្រី១៥៨នាក់ និងកម្រិតឧត្តមសិក្សាចំនួន៣៥នាក់ ស្រីចំនួន៩ នាក់។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន២៦នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន២នាក់ ស្រី១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៨០នាក់ ស្រី៣៤នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន៥ នាក់ ស្រី២នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន១៣នាក់ ស្រី៥នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទចំនួន៤១៣នាក់ ចំនួន២៨៣គ្រួសារ
- ធ្វើស្រែចំនួន៨១៧គ្រួសារ ដីទំហំ០,៥-២ហិកតា
- ធ្វើវារីវប្បកម្មចំនួន១០គ្រួសារ ស្រះចំនួន១០ស្រះ ទំហំ១៥មx២០ម x២,៥ម
- ជាងផ្ទះចំនួន ១២គ្រួសារ
- លក់ដូរចំនួន៣៥គ្រួសារ
- កម្មករ២៥គ្រួសារ
- មន្ត្រីរាជការ១៩គ្រួសារ
- ចិញ្ចឹមសត្វ២៤៨គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ១៣.៩៧៥.០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍គ្រួសារបីឃុំ ត្រូវបានលុបចេញពីអតីតឡូត៍នេសាទលេខ១១ក ដែននេសាទទឹកសាប ក្នុងខេត្តកំពង់ចាម មានទំហំ **៣.៦២៧** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
- ខាងត្បូងទល់នឹងឃុំព្រែកបាក់ និងឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
- ខាងកើតទល់នឹងឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
- ខាងលិចទល់នឹងទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទគ្រួសារបើយុំ មានបឹងចំនួន១៧បឹង ត្រពាំងចំនួន២ត្រពាំង ព្រែកចំនួន៤ ព្រែក និងទំនាបលិចទឹក គឺ៖

| | | | |
|---|---|---|---|
| - បឹងផ្សោត | ទំហំ ១៨,៨ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងប្រល័យ | ទំហំ ៤៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងលាក់គង | ទំហំ ១៤,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងអន្លង់ថ្ម | ទំហំ ១៧,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងថាស | ទំហំ ១,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងឆ្ដោរ | ទំហំ ៣,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងប្រលាន | ទំហំ ៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងដូនមាន់ | ទំហំ ៥,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងចក | ទំហំ ៣ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងប្រា | ទំហំ ១៧ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងត្រស់ | ទំហំ ៩ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងត្រស់ពាយ | ទំហំ ១០ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងផ្គាំធំ | ទំហំ ៧២,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងផ្គាំតូច | ទំហំ ៣៦,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងកូននាង | ទំហំ ៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងសង្វា | ទំហំ ៥,៥ | ហិកតា | ពេញមួយឆ្នាំ |
| - បឹងក្រសាំង | ទំហំ ៩ | ហិកតា | ពេញមួយឆ្នាំ |
| - ត្រពាំងតាសំ | ទំហំ ០,២៥ | ហិកតា | ពេញមួយឆ្នាំ |
| - ត្រពាំងរុន | ទំហំ ០,២ | ហិកតា | ពេញមួយឆ្នាំ |
| - ព្រែកកក | ទំហំ៦.៣៨៤ម x ២៥ម | | ពេញមួយឆ្នាំ |
| - ព្រែកស្រឡៅ | ទំហំ៥.៩២៦ម x ២៥ម | | ពេញមួយឆ្នាំ |
| - ព្រែកកក់ | ទំហំ២.៥៤៨ម x ២៥ម | | ពេញមួយឆ្នាំ |
| - ព្រែកបាក់ | ទំហំ២.៣៥៧ម x ២៥ម | | ពេញមួយឆ្នាំ |

- ដីទំនាបលិចទឹកមានទំហំសរុប ៣.៣០៥ ហិកតា។

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

បឹងផ្គាំតូច ទំហំ ៣៦,៥ ហិកតា ពេញមួយឆ្នាំ ។

**ឃ. ធនធានជលផល**

- ប្រភេទត្រី ៖

ត្រីរ៉ស់ ត្រីប្រា ត្រីឆ្ដោរ ត្រីឆ្លាំង ត្រីកែស ត្រីក្អែក ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លូញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ទ្រប់ ក្លាំងហាយ ត្រីខ្នាន់ ត្រីក្រឡង់ ត្រីសណ្ដាយ ត្រីអណ្ដែង ត្រីដំរី

ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្មៀត ត្រីកញ្ជ្រូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្ដាម ត្រីលលកសរ ត្រីឆ្កិន ត្រីបណ្ដូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្ដាតឆ្កែ ត្រីកញ្ចនដៃ កំពិស បង្កង ។ល។

- **ប្រភេទវារីសត្វ ៖**

អណ្ដើក ពស់ កង្កែប ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ក្ដាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

- **ប្រភេទរុក្ខជាតិព្រៃលិចទឹកនិងវារីរុក្ខជាតិ ៖**

ដើមថ្លើមអណ្ដើក ខ្លុបយក្ស(អូយយ៉ាស់/បន្ទាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំថ្កែង អញ្ចាញ ត្នួ ស្មែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ខ្នាយមាន់ វល្លិប្រេង វល្លិទឹកដោះ វល្លិត្រដិត វល្លិដោះគន់ វល្លិត្រី វល្លិត្អើក អំពាក់ទឹក ស្លាបទា កន្ទាំងហែ ស្នោ ស្លូត បន្លាឃ្លេ ថ្វាន់ ស្នូលទឹក ច្រកែង ប្រផេញ ផ្ដៅ ផ្អែកព្រាប វល្លិអណ្ដាតគ្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្ពន់អំបោះ ត្រាវអណ្ដែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំប្លង កក់ជ្រុង កក់ក្ដាម ឈូក ចន្ទល់ភ្នំ(វល្លិថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៤១៣នាក់ ស្រី៨៥នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍ មានចំនួន៥១៥នាក់ ស្រី៩២នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៥៧នាក់ ស្រី៨នាក់។

### ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៥៨ | ១០០-១.០០០ម/គ្រួសារ | ៨៦.៩០០ម៉ែត្រ | ពេញរដូវនេសាទ |
| សន្ទូចរនង | ផ្លែ | ៣២ | ២០០-៥០០ផ្លែ/គ្រួសារ | ១១.២០០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| សន្ទូចបង្កៃ | ផ្លែ | ២៤ | ៥០-១០០ផ្លែ/គ្រួសារ | ១.៨០០ផ្លែ | ពេញរដូវនេសាទ |
| សៃយ៉ឺនឫស្សី | គ្រឿង | ១៨ | ៤-១០គ្រឿង/គ្រួសារ | ១២៦គ្រឿង | ខែសីហា ដល់ ខែវិច្ឆិកា |
| លបឫស្សី | គ្រឿង | ១៤ | ៨-២០គ្រឿង/គ្រួសារ | ១៩៦គ្រឿង | ខែសីហា ដល់ ខែធ្នូ |
| សំណាញ់ | វង់ | ៧៥ | ១វង់/គ្រួសារ | ៧៥វង់ | ពេញរដូវនេសាទ |
| អួនអូសដៃ | វង់ | ២០ | ៣០-៨០ម/១វង់/គ្រួសារ | ១.១០០ម/២០វង់ | ខែមករា ដល់ ខែឧសភា |
| លាន់ | គ្រឿង | ២៨ | ១៥-៥០គ្រឿង/គ្រួសារ | ៩១០គ្រឿង | ខែកក្កដា ដល់ ខែកញ្ញា |
| ឆ្នុក | គ្រឿង | ១៥ | ១គ្រឿង/គ្រួសារ | ១៥គ្រឿង | ខែវិច្ឆិកា ដល់ ខែមីនា |

| | | | | | |
|---|---|---|---|---|---|
| តុម | គ្រឿង | ១៦ | ២គ្រឿង/គ្រួសារ | ៣២គ្រឿង | ខែកក្កដា ដល់ ខែកញ្ញា |
| ឈ្នាងរុញលៀស | គ្រឿង | ១៧ | ១គ្រឿង/គ្រួសារ | ១៧គ្រឿង | ខែមករា ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២៣៤គ្រឿង | ២០០-៤០០គីឡូក្រាម | ៥,៥-១៨សេះ |
| ទូកអុំ និងចែវ | ៣១គ្រឿង | ៥០-១០០គីឡូក្រាម | |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៩៥ | ១០០-១.០០០ម/គ្រួសារ | ៥២.២៥០ម៉ែត្រ | ពេញរដូវនេសាទ |
| សន្ទូចរនង | ផ្លែ | ៣៦ | ២០០-៥០០ផ្លែ/គ្រួសារ | ១២.៦០០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| សន្ទូចបង្កៃ | ផ្លែ | ២៧ | ៥០-១០០ផ្លែ/គ្រួសារ | ២.០២៥ផ្លែ | ពេញរដូវនេសាទ |
| សៃយ៉ឹនឫស្សី | គ្រឿង | ១៥ | ៤-២០គ្រឿង/គ្រួសារ | ១៨០គ្រឿង | ខែសីហា ដល់ ខែធ្នូ |
| លបឫស្សី | គ្រឿង | ១៨ | ៨-២០គ្រឿង/គ្រួសារ | ២៥២គ្រឿង | ខែសីហា ដល់ ខែធ្នូ |
| សំណាញ់ | វង់ | ៥៩ | ១វង់/គ្រួសារ | ៥៩វង់ | ពេញរដូវនេសាទ |
| អួនអូសដៃ | វង់ | ៨ | ៣០-៨០ម/១វង់/គ្រួសារ | ៤៤០ម/៨វង់ | ខែមករា ដល់ ខែឧសភា |
| លាន់ | គ្រឿង | ១២ | ១០-៥០គ្រឿង/គ្រួសារ | ៣៦០គ្រឿង | ខែកក្កដា ដល់ ខែកញ្ញា |
| ឆ្នុក | គ្រឿង | ១០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ខែវិច្ឆិកា ដល់ ខែមីនា |
| តុម | គ្រឿង | ២៥ | ២គ្រឿង/គ្រួសារ | ៥០គ្រឿង | ខែកក្កដា ដល់ ខែកញ្ញា |
| ឈ្នាងរុញលៀស | គ្រឿង | ១៥ | ១គ្រឿង/គ្រួសារ | ១៥គ្រឿង | ខែមករា ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២៩១គ្រឿង | ២០០-៤០០គីឡូក្រាម | ៥,៥-១៨សេះ |
| ទូកអុំ និងចែវ | ៤៩គ្រឿង | ៥០-១០០គីឡូក្រាម | |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៣៥ | ១០០-១.០០០ម/គ្រួសារ | ១៩.២៥០ម៉ែត្រ | ពេញរដូវនេសាទ |
| សន្ទូចរនង | ផ្លែ | ១៦ | ២០០-៥០០ផ្លែ/គ្រួសារ | ៥.៦០០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| សំណាញ់ | វង់ | ១៤ | ១វង់/គ្រួសារ | ១៤វង់ | ពេញរដូវនេសាទ |
| លាន់ | គ្រឿង | ៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣៧៥គ្រឿង | ខែកក្កដា ដល់ ខែកញ្ញា |
| អួនអូសដៃ | វង់ | ៣ | ៤០-១០០ម/១វង់/គ្រួសារ | ២១០ម/៣វង់ | ខែមករា ដល់ ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥៧គ្រឿង | ៣០០-១.០០០គីឡូក្រាម | ៧-១៨សេះ |
| | | | |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ៦៣៥គីឡូក្រាម | ៣៨៩គីឡូក្រាម | ១.០២៤គីឡូក្រាម |
| ខ្ចៅ លៀស | ៨១៥គីឡូក្រាម | | ៨១៥គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនវិស័យ ៖**

សហគមន៍នេសាទគ្រួសារបីឃុំ មានទស្សនវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវជំនឿង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គ្រួសារបីឃុំ គឺរៀបចំឡើងដោយគិតគូពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| ប្រើប្រាស់ក្នុងបឹង | កក្កដាដល់តុលា | មងរាយ | ១០០ម/គ្រួសារ | ៥០.០០០ម៉ែត្រ | សមាជិកសហគមន៍និង |

| | | | | | |
|---|---|---|---|---|---|
| ព្រៃក គ្រពាំង នានា និងទំនាបលិចទឹក កន្លែងនេសាទ សហគមន៍គ្រួសារ បីឃុំ | វិច្ឆិកាដល់មិថុនា | | ៣០០ម/គ្រួសារ | ១៥០.០០០ម៉ែត្រ | អ្នកមិនសមាជិកសហគមន៍ |
| | កក្កដាដល់ធ្នូ | សន្ទូចរនង | ៣០០ផ្លែ/គ្រួសារ | មិនកំណត់ | |
| | ពេញរដូវនេសាទ | សន្ទូចបង្កៃ | ៧៥/គ្រួសារ | មិនកំណត់ | |
| | ពេញរដូវនេសាទ | សន្ទូចស្ទូច | មិនកំណត់ | មិនកំណត់ | |
| | សីហាដល់ធ្នូ | សៃយ៉ឺនឫស្សី | ៤គ្រឿង/គ្រួសារ | ៤០គ្រួសារ | |
| | សីហាដល់ធ្នូ | លបឫស្សី | ៦គ្រឿង/គ្រួសារ | ៣០គ្រួសារ | |
| | ពេញរដូវនេសាទ | សំណាញ់ | មិនកំណត់ | មិនកំណត់ | |
| | មករាដល់ឧសភា | អួនអូសដៃ | ៣០ម/១វង់/គ្រួសារ | ១៥គ្រួសារ | |
| | កក្កដាដល់កញ្ញា | លាន់ | ៥០គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ពេញរដូវនេសាទ | អង្រុត | មិនកំណត់ | ១០០គ្រួសារ | |
| | ពេញរដូវនេសាទ | ថ្នង | មិនកំណត់ | មិនកំណត់ | |
| | វិច្ឆិកាដល់មីនា | ឆ្នុក | ១គ្រឿង/គ្រួសារ | មិនកំណត់ | |
| | កក្កដាដល់កញ្ញា | ត្រុម | ២គ្រឿង/គ្រួសារ | មិនកំណត់ | |
| | មករាដល់មេសា | ឈ្នាងរុញលៀស | ១គ្រឿង/គ្រួសារ | មិនកំណត់ | |

**គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍**

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម - បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ គ្រួសារបីឃុំ | ៣.៦២៧ ហិកតា | ៣.៦២៧ ហិកតា | ចុះស្វែងរកចំណុចទីតាំងជាក់ស្តែងលើផែនដី តាមនិយាមកាលើផែនទីឬប្រកាស | ២០០ | ២០១៨ - ២០១៩ |
| | | | ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | ២០០ | ២០១៨ - ២០១៩ |
| | | | សាងសង់បង្គោលធ្វើពីស៊ីម៉ង់ដោយសរសេរអក្សរលើបង្គោល ចំនួន៧បង្គោល | ១.២០០ | ២០១៨ - ២០១៩ |
| បឹងប្រា | ១៧ហិកតា | ៥០មx២៣០ម x២ម= ២៣.០០០ម៣ | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៨ - ២០១៩ |
| | | | កំណត់ទីតាំង | ១០០ | ២០១៨ - ២០១៩ |
| | | | បោះបង្គោលព្រំទីតាំងស្តារ ៦ បង្គោលនិងសរសេរស្លាកសញ្ញា | ២១០ | ២០១៨ - ២០១៩ |
| | | | គ្រឿងចក្រស្តារឡើងវិញ និងដឹកចំនួន ៥.៧៥០ឡាន x ៥$ | ២៨.៧៥០ | ២០១៨ - ២០១៩ |
| | | | អាចម៍ដីរៀបចំទំនប់បឹងប្រា | | |
| | | | ដាំព្រៃលិចទឹក(រាំង ត្រស់ សណ្តាន់) ចំនួន១០០ដើម | ៥០០ | ២០១៨ - ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| | | | ថែទាំ ការពារ | | ២០១៨ - ២០២០ |
| បឹងចក (ស្តារដៃបឹងចក) | ៣ហិកតា | ៤០មx៣០០មx៣ម= ៣៦.០០០ម$^{៣}$ | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៩ - ២០២០ |
| | | | កំណត់ទីតាំង | ១០០ | ២០១៩ - ២០២០ |
| | | | បោះបង្គោលព្រំបេតុង៦បង្គោល និងសរសេរស្លាកសញ្ញា | ២១០ | ២០១៩ - ២០២០ |
| | | | គ្រឿងចក្រស្តារឡើងវិញ | ៤៥.០០០ | ២០១៩ - ២០២០ |
| | | | អាចម៍ដីរៀបចំមាត់បឹងជាទំនប់ | | |
| | | | ដាំព្រៃលិចទឹក(រាំង ត្រស់ សណ្តាន់) ចំនួន ១០០ដើម | ៥០០ | ២០១៩ - ២០២០ |
| | | | ថែរក្សា ការពារ | | |

**គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស**

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែនសនេសាទ | ទំហំត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងផ្គាំតូច | ១ហិកតា | -ព្រៃលិចទឹក<br>-ត្រីមេពូជ | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (មួយលើក/ឆ្នាំ) | ២០០ | ២០១៨ | ២០១៩ |
| | | | បោះបង្គោលព្រំស៊ីម៉ង់តំបន់អភិរក្សចំនួន៣បង្គោល | ៣.៦០០ | ២០១៨ | ២០១៩ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣០០ | ២០១៨ | ២០១៩ |
| | | | សាងសង់ប៉មយាមរួមជាមួយបង្គោលព្រំអភិរក្ស | ១.៤០០ | ២០១៨ | ២០១៩ |

**គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក**

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើងវិញ ដោយដកហូតមកវិញដីព្រៃលិចទឹក ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| -ចំណុចទំនប់កោសខ្យល់<br>-ចំណុចត្រពាំងផ្តៅ<br>-បឹងផ្សោត<br>-បឹងប្រល័យ | - ២០<br>- ១០<br>- ១៨,៨<br>- ៤៥ | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ចែកឯកសារ | ៥០០ | ២០១៨ | ២០១៩ |
| | | | | ប្រជុំ | ៨០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| -បឹងកូននាង<br>-បឹងត្រស់ពាយ | - ៥<br>- ១០ | | ចុះកំណត់ទីតាំងជាក់ស្តែង | ៥០០ | ២០១៨ | ២០១៩ |
| | | | រៀបចំឯកសារដកហូតដីព្រៃលិចទឹកទៅអាជ្ញាធរ | ១.០០០ | ២០១៨ | ២០១៩ |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន ១០០ បង្គោល (ធ្វើពីស៊ីម៉ង់ ទំហំ ០,២ម x ០,២មx ១,៥ម x ជើងតាង០,៦ម៉ែត្របួនជ្រុង) និងសរសេរស្លាកសញ្ញា | ៣.៥០០ | ២០១៩ | ២០២០ |

**គ៥-ផែនការទប់ស្កាត់បទល្មើសជលផល**

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ (មិថុនា/រៀងរាល់ឆ្នាំ) | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ និងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ៦០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញ | ២០១៨ | ២០២០ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការ ប្រចាំខែនិងឆមាស រៀងរាល់ឆ្នាំ | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ៣០០<br>(២ដង/ឆ្នាំ) | -គណៈកម្មការ<br>-ក្រុមល្បាត<br>-អាជ្ញាធរមូលដ្ឋាន<br>-អង្គភាពពាក់ព័ន្ធ | ២០១៨ | ២០២០ |
| អនុវត្តន៍ផែនការ៖<br>(រៀបចំកំលាំងចុះ បង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ) (៤ដង/ខែ = ១២០/ដង) ជាប្រចាំលើកលែងខែមិថុនា-កក្កដា | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៨.៦៤០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | ២០១៨ | ២០២០ |

| | | | | | |
|---|---|---|---|---|---|
| យុទ្ធនាការបង្ក្រាបបទល្មើសនេសាទ | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៧.៤៧១ (២ខែ/ឆ្នាំ) | ក្រុមល្បាតស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | មិថុនា-សីហា/ ២០១៨ | មិថុនា-សីហា/ ២០២០ |
| | ប្រេងសាំងនិងប្រេងបាត | ៧២០ (២០លីត្រ/ថ្ងៃ) | | | |
| មធ្យោបាយនិងសម្ភារ ៖<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយឺត | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ៣.៣៤៦ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការ | ២០១៨ | ២០១៩ |
| ទិញទូកម៉ាស៊ីនថ្មីចំនួន២គ្រឿង | មានមធ្យោបាយចុះល្បាត | ៣.០០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការ | ២០១៨ | |

**គ៦-ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ**

ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទីពីរនៃខែ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត | ៦៦៥ | -គណៈកម្មការ<br>-ក្រុមល្បាត | ២០១៨ | ២០២០ |
| ប្រជុំជាមួយអាជ្ញាធរឃុំឬស្ថាប័នពាក់ព័ន្ធ (១៧-២៦/រៀងរាល់ខែ) | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលសម្រេចបាន<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍ឃុំនិងផែនការស្ថាប័នពាក់ព័ន្ធ | ៥៤៥ | -អាជ្ញាធរឃុំ<br>-ស្ថាប័នពាក់ព័ន្ធ<br>-គណៈកម្មការ | ២០១៨ | ២០២០ |
| -សម្ភារការិយាល័យ<br>-ទិញក្រដាស់ ប៊ិច<br>-ព្រីនឯកសារ កូបពី<br>-ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ៣៥០ | គណៈកម្មការ | រយៈពេល៣ឆ្នាំ | |

**គ៧-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល**

ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើងដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ ដូចមានខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **ផែនការផ្សព្វផ្សាយ** | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី៖<br>-ច្បាប់ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងស.ន ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តន៍តាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តន៍តាមផែនការនិងវិធានច្បាប់នានា ដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឲ្យជីវភាពធូរធារ | ១.៥០០ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | មេសា-មិថុនា/រៀងរាល់ឆ្នាំ | |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៥០០ | | ២០១៨ | ២០២០ |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៥០ | | ២០១៨ | ២០២០ |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជនចូលរួមសហគមន៍នេសាទគ្រួសារបីឃុំ | មានយុវជនចូលរួមក្នុងការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ១.០០០ | សមាជិកសហគមន៍នេសាទ | ២០១៨ | ២០១៩ |
| **ផែនការបណ្តុះបណ្តាល** | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈកម្មការសមាជិកស.ន ប្រជាពលរដ្ឋបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ | ២០១៨ | ២០១៩ |
| វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កំព្យូទ័រ | គណៈសហគមន៍នេសាទ (២នាក់) | ៥០០ | គណៈកម្មការ ស.ន | ២០១៨ | |
| វគ្គបណ្តុះបណ្តាលពី៖<br>-ការគ្រប់គ្រង និងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធាន | គណៈកម្មការនិងសមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិត បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៦៥០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៨ | |
| វគ្គបណ្តុះបណ្តាលយេនឌ័រ និងការវិភាគយេនឌ័រ | គណៈកម្មការសមាជិកស.ន ប្រជាពលរដ្ឋបានយល់ដឹង និងអាច | ៤០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៩ | |

| | | | | |
|---|---|---|---|---|
| | អនុវត្តន៍បានក្នុងការងារជាក់ស្តែង | | អាជ្ញាធរមូលដ្ឋាន | |
| វគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ | គណៈកម្មការសមាជិកស.ន ប្រជាពលរដ្ឋបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០១៩ |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់ | គណៈកម្មការសមាជិកស.ន ប្រជាពលរដ្ឋបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០២០ |
| វគ្គបណ្តុះបណ្តាលវិធីសាស្រ្តការប្រមូលព័ត៌មាន | គណៈកម្មការសហគមន៍នេសាទបានយល់ដឹងនិងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការស.ន | ២០២០ |

**គ៨- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ**

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹម (ត្រី កង្កែប អន្ទង់) | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក) | | ១.៥០០ | | ២០១៨ | ២០១៩ |
| កែច្នៃផលនេសាទ | | ១.៥០០ | | ២០១៨ | ២០១៩ |
| បច្ចេកទេសដាំបន្លែ | | ១.៥០០ | | ២០១៨ | ២០១៩ |
| បច្ចេកទេសកសិកម្មចម្រុះនិងកសិកម្មបន្ត | | ៩០០ | | ២០១៨ | ២០១៩ |
| បច្ចេកទេសកែច្នៃសម្ភារប្រើប្រាស់និងសិប្បកម្ម | | ១.០០០ | | ២០១៨ | ២០១៩ |
| ទស្សនកិច្ចសិក្សា | ទទួលបានបទពិសោធន៍បន្ថែម | ២.៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |
| ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹមសត្វ (មាន់ ទា ជ្រូក) | -មានក្រុមចិញ្ចឹមសត្វ<br>-មានបន្លែផ្គត់ផ្គង់ដល់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |
| ក្រុមកែច្នៃផលនេសាទ ដោយផ្តោតលើ ៖<br>-ក្រុមស្ត្រី<br>-ជនងាយរងគ្រោះក្នុងស.ន | -មានក្រុមកែច្នៃផលនេសាទ<br>-មានផលិតផលផលផលផ្គត់ផ្គង់ដល់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |
| ក្រុមដាំបន្លែ | -មានក្រុមដាំបន្លែ<br>-មានបន្លែផ្គត់ផ្គង់ដល់ទីផ្សារ | ៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| ក្រុមកសិកម្មចម្រុះ និងកសិកម្មបន្ត | -មានក្រុមកសិកម្មចម្រុះនិងបន្ត<br>-មានដំណាំចម្រុះផ្គត់ផ្គង់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |
| ក្រុមកែច្នៃសម្ភារប្រើប្រាស់និងសិប្បកម្ម | -មានក្រុមកែច្នៃសម្ភារប្រើប្រាស់និងសិប្បកម្ម<br>-មានសម្ភារប្រើប្រាស់ធ្វើពីឫស្សីផ្គត់ផ្គង់ដល់ទីផ្សារ | ៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |

**គ៩- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ**

ផែនការបង្កើតក្រុមឥណទាន ដើម្បីបង្កើនមុខរបរ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **ក្រុមសន្សំប្រាក់** | | | | | |
| ផ្សព្វផ្សាយ ជ្រើសរើសសមាជិកក្រុមសន្សំប្រាក់ | ក្រុមសន្សំប្រាក់ស.នគ្រួសារបីឃុំត្រូវបានបង្កើតឡើង ដោយមានការចូលរួមពីសមាជិកស.ន | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមសន្សំប្រាក់ | -មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមសន្សំប្រាក់<br>-មានដំណើរការល្អ (ខ្ចី សង) | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ផ្តល់ប្រាក់កំចីនិងប្រមូលប្រាក់សន្សំ | មានទុនសម្រាប់ចាប់ផ្តើមមុខរបរ | ២.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ប្រជុំប្រចាំខែ | -របាយការណ៍សាច់ប្រាក់<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមសន្សំ | ២០១៨ | ២០២១ |
| **ក្រុមឥណទានប្រេង** | | | | | |
| ផ្សព្វផ្សាយជ្រើសរើសសមាជិកក្រុមឥណទានប្រេង | ក្រុមសន្សំប្រាក់ស.ន ត្រូវបានបង្កើតឡើង ដោយមានការចូលរួមពីសមាជិកស.ន | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមឥណទានប្រេង | -មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទានប្រេង<br>-មានដំណើរការល្អ (ខ្ចី សង) | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ផ្តល់ឥណទាននិងប្រមូលបដិភាគ | មានឥណទានដើម្បីចាប់ផ្តើមមុខរបរ | ២.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ប្រជុំប្រចាំខែ | -របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមឥណទានប្រេង | ២០១៨ | ២០២១ |

**គ១០- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ**

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោមៈ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ | -សមាជិកស.ន អ្នកពាក់ពាន់មានការឯកភាព គាំទ្រនិងចូលរួម<br>-អនុវត្តន៍បានតាមផែនការ | ២០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៨ | ២០១៩ |
| សាងសង់ស្នាក់ការ សហគមន៍នេសាទ ទំហំ៦មx៨ម ធ្វើពីបេតុង គ្រឿងដែក ប្រក់ក្បឿង ដោយមានបង្គន់អនាម័យ | - សហគមន៍នេសាទមានកន្លែងធ្វើការងារសហគមន៍<br>-បង្កើនប្រាក់ចំណូល និងលើកតម្កើងជីវភាពសមាជិកសហគមន៍នេសាទ | ៩.៥០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៨ | ២០១៩ |
| រៀបចំប្រព័ន្ធទឹកស្អាត (រៀបចំអាង) | មានទឹកស្អាតសម្រាប់ប្រើប្រាស់ | ១.៥០០ | | ២០១៨ | ២០១៩ |

**គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ**

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ប៉ាន់ស្មានតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមស្រះ (១៦គ្រួសារ) | ១៦សx១៥មx២០មx២,៥ម | អណ្តែង ប្រា ឆ្លិន កាប | ៥.០០០/ស្រះ | ៦.០០០ | ២០១៨ | ២០២០ |
| ចិញ្ចឹមកង្កែប អន្ទង់ តាមអាង (១០គ្រួសារ) | ៥អx២មx១,៥មx១,២ម | អន្ទង់ | | ៦២៥ | ២០១៨ | ២០២០ |
| | ៥អx២មx១,៥មx១,២ម | កង្កែប | | ៥០០ | ២០១៨ | ២០២០ |

គ១២-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ១.០០០រៀល/ម្នាក់ | ២០១៨ | ២០២០ | ៣៣៦,២៥ | ១.០០០រៀល/នាក់ (១.៣៤៥នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំសមាជិកស.ន ២០.០០០រៀល/ម្នាក់ | ២០១៨ | ២០២០ | ៦.១៩៥ | សមាជិកអ្នកនេសាទ ៤១៣នាក់ x ២០.០០០ រៀល/ម្នាក់) |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ | ប្រមូលប្រាក់កម្រៃពី អ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ ៤០.០០០រៀល/ទូក/រដូវ | ២០១៨ | ២០២០ | ១.៧១៦ | 10% នៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅចំនួន ៥៧២ នាក់ |
| សរសេរគម្រោងស្នើសុំថវិកាពី ៖<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូពាក់ព័ន្ធ<br>-សប្បុរសជន | -ទំនាក់ទំនងជាមួយមន្ទីរពាក់ព័ន្ធជុំវិញខេត្ត អង្គការដៃគូពាក់ព័ន្ធ និងសប្បុរសជន<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដាននិងវាយតម្លៃ | ២០១៨ | ២០២០ | ១៥២.២២៤,៧៥ | សរសេរគម្រោងស្នើសុំថវិកាចំណាយ ៥០០ដុល្លា |
| សរុប | | | | ១៦០.៤៧២ | |

### ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការរួមមានសមាជិក គណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសបញ្ហា នេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្សព្រៃ លិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបាន ការឧបត្ថម្ភគាំទ្របច្ចេកទេសនិងថវិការសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការអនុវត្តន៍ផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ អ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសម្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គ្រួសារបីឃុំ រយៈពេល ៣ ឆ្នាំ ( មីនា ២០១៨ ដល់ កុម្ភៈ ២០២១)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទដោយឧបករណ៍នេសាទគ្រួសារ | -មាននិរន្តរភាពធនធាន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៨ | ២០២០ | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | -ស្វែងរកចំណុចទីតាំងជាក់ស្តែងលើផែនដីតាមនិយាមកាលើផែនទី/ប្រកាស<br>-ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>-សាងសង់បង្គោលព្រំស.ន ធ្វើពីស៊ីម៉ង់និងសរសេរអក្សរលើបង្គោល | -ស្គាល់ចំណុចទីតាំងលើផែនដីដើម្បីបោះបង្គោលព្រំ<br>-សមាជិកស.នបានស្គាល់ព្រំប្រទល់កន្លែងនេសាទសហគមន៍បានច្បាស់លាស់<br>-កាត់បន្ថយការរំលោភយកដីព្រៃ | ១.៦០០ | - ស.ន.គ.ប.ឃ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | -ប្រជុំផ្សព្វផ្សាយ<br>-កំណត់ទីតាំងជាក់ស្តែង<br>-បោះបង្គោលព្រំធ្វើពីបេតុងនិងដាក់ស្លាកសញ្ញាទីតាំងស្តារនិងដាំព្រៃ<br>-ប្រើគ្រឿងចក្រស្តារឡើងវិញ<br>-អាចម៍ដីរៀបចំទនប់បឹងប្រា<br>-ដាំព្រៃលិចទឹក រាំង ត្រស់ សណ្តាន់<br>-ថែរក្សា ការពារ | -ត្រីមានជម្រក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-ត្រីកើន<br>-មានទឹកប្រើប្រាស់ | ៧៥.៥៧០ | | ២០១៨ | ២០២០ | ស្តារ២ទីតាំង |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-បោះបង្គោលព្រំធ្វើពីស៊ីម៉ង់<br>-ដាក់ស្លាកសញ្ញា<br>-សាសង់ប៉មយាម | -មានត្រីមេពូជ<br>-ត្រីកើនឡើងវិញ<br>-ព្រៃលិចទឹកកើនឡើងវិញ | ៥.៥០០ | - ស.ន.គ.ប.ឃ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ<br>-ចុះកំណត់ទីតាំងជាក់ស្តែង<br>-រៀបចំឯកសារស្នើសុំដកហូតដីព្រៃ | -ស្គាល់ច្បាស់ព្រំព្រៃលិចទឹក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-មានជម្រកត្រីរស់នៅ | ២.៨០០ | - ស.ន.គ.ប.ឃ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ | ២០១៨ | ២០១៩ | |
| | បោះបង្គោលព្រំព្រៃនិងដាក់ស្លាកសញ្ញា | | ៣.៥០០ | | ២០១៩ | ២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-អនុវត្តផែនការចុះបង្ក្រាបដល់ទីកន្លែង<br>-យុទ្ធនាការបង្ក្រាបបទល្មើសជលផល | -បទល្មើសថយចុះ<br>-ធនធានព្រៃលិចទឹក និងត្រីកើនឡើងវិញ<br>-ផលចាប់ត្រីបានច្រើន | ១៧.០១១ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២១ | |
| | ទិញមធ្យោបាយនិងសម្ភារប្រើប្រាស់ | មានមធ្យោបាយ សម្ភារល្បាត | ៧.០៦៦ | | ២០១៨ | ២០១៩ | |
| គ៦.ផែនការប្រជុំប្រចាំខែ និងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការស.ន | -ប្រជុំគណៈកម្មការស.ន<br>-ប្រជុំជាមួយឃុំឬស្ថាប័ន<br>-ទិញសម្ភារការិយាល័យ | -របាយការណ៍លទ្ធផល<br>-មានអន្តរាគមន៍ពីឃុំនិងស្ថាប័ន<br>-មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ១.៥៦០ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២១ | |
| គ៧.ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជនចូលជាសមាជិកសហគមន៍នេសាទ | -មានក្រុមយុវជនចូលរួមក្នុងស.ន<br>-គណៈកម្មការ សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមានការយល់ដឹង<br>-អាចយកទៅអនុវត្តន៍បាន ដោយមានការចូលរួម<br>-មានការគ្រប់គ្រងល្អ ធនធានជលផលសម្បូរឡើងវិញ | ៣.១៥០ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | ផ្សព្វផ្សាយ (ប្រជុំ បិទផ្សាយ ចែកឯកសារ)៖ ជលផល, ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ននិងផែនការគ្រប់គ្រងសហគមន៍នេសាទ | | | | ២០១៨ | ២០២០ | |
| | បណ្តុះបណ្តាលស្តីពីការ ៖<br>-របាយការណ៍ កំណត់ហេតុ<br>-គម្រោងស្នើសុំនិងការគ្រប់គ្រងថវិកា<br>-ប្រើប្រាស់កំព្យូទ័រ<br>-គ្រប់គ្រងនិងសារៈសំខាន់នៃធនធាន<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ<br>-យេនឌ័រនិងការវិភាគយេនឌ័រ<br>-ប្រែប្រួលអាកាសធាតុ<br>-សម្របសម្រួលនិងដោះស្រាយទំនាស់<br>-ការប្រមូលព័ត៌មាន | | ៤.៤៥០ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៨.ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍ | បណ្តុះបណ្តាលស្តីពីបច្ចេកទេសៈ<br>-ចិញ្ចឹម(ត្រី អន្ទង់ និងកង្កែប)<br>-ចិញ្ចឹម(មាន់ ទា និងជ្រូក)<br>-កែច្នៃផលនេសាទ<br>-ការដាំបន្លែ<br>-កសិកម្មចម្រុះនិងកសិកម្មបន្ត<br>-ការកែច្នៃសម្ភារប្រើប្រាស់និងសិប្បកម្ម<br>-ទស្សនកិច្ចសិក្សា | -មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ<br>-អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ<br>-ទទួលបានប្រាក់ចំណូលបន្ថែម | ១០.៤០០ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | បង្កើតក្រុមមុខរបរៈ<br>-ក្រុមចិញ្ចឹមមាន់ ទា និងជ្រូក<br>-ក្រុមកែច្នៃផលនេសាទ<br>-ក្រុមដាំបន្លែឬដំណាំចំការ<br>-ក្រុមកសិកម្មចម្រុះនិងកសិកម្មបន្ត<br>-ក្រុមកែច្នៃសម្ភារប្រើប្រាស់/សិប្បកម្ម | -មានក្រុមមុខរបរកើតឡើង<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ២.៥០០ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ៩.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | -ផ្សព្វផ្សាយជ្រើសរើសអ្នកស្ម័គ្រចិត្ត<br>-បង្កើតក្រុមឥណទាន<br>-រៀបចំរចនាសម្ព័ន្ធក្រុមឥណទាន<br>-ប្រជុំរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនតម្កល់<br>-ចូលរួមប្រាក់សន្សំនិងបដិភាគ | -មានក្រុមឥណទាន<br>-មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ(ខ្ចី សង)<br>មានទុនចាប់ផ្តើមមុខរបរ<br>-របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ៦.៥៤០ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | ប្រជុំប្រចាំខែ | | | | ២០១៨ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ១០.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | -សាងសង់ស្នាក់ការ<br>-រៀបចំបណ្តាញអគ្គីសនី<br>-រៀបចំប្រព័ន្ធទឹកស្អាត<br>-ទិញសម្ភារ | - សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ<br>-មានសម្ភារប្រើប្រាស់<br>-សម្រេចបានសកម្មភាពការងារ | ១១.២០០ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | -ចិញ្ចឹមត្រីតាមស្រះ<br>-ចិញ្ចឹមកង្កែបនិងអន្ទង់តាមអាង<br>-ទិញកូនត្រីពូជ | -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានផលិតផលត្រីផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ៧.១២៥ | - ស.ន.គ.ប.យ<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២០ | |
| គ១២.ផែនការថវិកាទ្រទ្រង់សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- កម្រៃពីអ្នកខាងក្រៅ | មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ | ១៦០.៤៧២ | - រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២០ | |
| | សរសេរគម្រោងស្នើសុំរាជរដ្ឋាភិបាលសប្បុរសជន អង្គការដៃគូ | | | | ២០១៨ | ២០២០ | |

| សកម្មភាព | ២០១៨ | | | | | | | | | ២០១៩ | | | ២០២០ | | | ២០២១ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | កុម្ភៈ |
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | → | → | → | → | → | → | → | → | → | → | → | → | | | | | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារការិយាល័យ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | | | | | |
| គ៩.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ១០.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | | | | | |
| គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ១២.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |

សូមគោរពជូន
លោកមេឃុំពាក់ព័ន្ធ
«ដើម្បីជូនពិនិត្យនិងសម្រួល»
ថ្ងៃ.........ខែ.........ឆ្នាំ.........ស័ក ព.ស.........
.........ថ្ងៃទី.........ខែ.........គ.ស.........
ប្រធានគណៈកម្មការសហគមន៍នេសាទ
គ្រួសារបីឃុំ

លេខ.........
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម
«ដើម្បីជូនពិនិត្យនិងសម្រួល»
ថ្ងៃ.........ខែ.........ឆ្នាំ.........ស័ក ព.ស.........
ព្រែកបាក់ថ្ងៃទី.........ខែ.........គ.ស.........
មេឃុំព្រែកបាក់

លេខ.........
ថ្ងៃ.........ខែ.........ឆ្នាំ.........ស័ក ព.ស.........
ព្រែកកក់ថ្ងៃទី.........ខែ.........គ.ស.........
មេឃុំព្រែកកក់

លេខ..................

បានឃើញនិងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម

«ដើម្បីជូនពិនិត្យនិងសម្រួល»

ថ្ងៃ..................ខែ..............ឆ្នាំ..............ស័ក ព.ស..............

កំពង់ចាម ថ្ងៃទី..............ខែ..............គ.ស..............

នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម

អ៊ុក_ណារិន

លេខ..................ជផ

បានឃើញនិងឯកភាព

ថ្ងៃ..................ខែ..............ឆ្នាំ..............ស័ក ព.ស..............

រាជធានីភ្នំពេញ ថ្ងៃទី..............ខែ..............គ.ស..............

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន

លេខ..................

ថ្ងៃ..................ខែ..............ឆ្នាំ..............ស័ក ព.ស..............

ទួលព្រះឃ្លាំង ថ្ងៃទី..............ខែ..............គ.ស ២០១៧

**មេឃុំទួលព្រះឃ្លាំង**

ស្រី_មើង

លេខ..................

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

«ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ»

ថ្ងៃ..................ខែ..............ឆ្នាំ..............ស័ក ព.ស..............

កំពង់ចាម ថ្ងៃទី..............ខែ..............គ.ស..............

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម

គឹម_សារឿន